# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

ថ្ងៃសុក្រ ១៣រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ

ក្រសួងមុខងារសាធារណៈ បានរៀបចំ **«សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤»** នាថ្ងៃទី៣ និងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤។ សន្និបាតនេះរៀបចំឡើងក្នុងគោលបំណង ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលក្រសួងសម្រេចបាននៅក្នុងឆ្នាំកន្លងមក និងដាក់ចេញទិសដៅការងារសម្រាប់ការដឹកនាំ និងគ្រប់គ្រងវិស័យមុខងារសាធារណៈ សំដៅរួមចំណែកដល់ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ។

នាព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើក ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ និងតំណាងក្រសួង-ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទូទាំងប្រទេស ប្រមាណជាង ៧០០នាក់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបានសមិទ្ធផលធំៗជាច្រើនដូចជា៖ (១)ការពិនិត្យ និងវាយតម្លៃឡើងវិញរចនាសម្ព័ន្ធអង្គភាព មុខងាររបស់ខ្លួន និងការកែទម្រង់ផ្ទៃក្នុងក្រសួង, (២)ការដាក់ចេញជាបន្តបន្ទាប់នូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានមនុស្ស, (៣)ការជំរុញ និងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការរបស់ក្រសួង-ស្ថាប័ន (៤)ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រងមន្ត្រីរាជការ (៥)ការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល ជាពិសេសការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ (៦)ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័នតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល (៧)ការរៀបចំសេចក្តីព្រាងផែនការសកម្មភាព ក្នុងការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា សម្រាប់ឆ្នាំ២០២៤ ដល់ ២០២៨ និងការពិនិត្យឡើងវិញនូវសេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ធ្វើបច្ចុប្បន្នភាពឱ្យបានសមស្រប ដើម្បីប្រើប្រាស់ជាផែនទីចង្អុលផ្លូវរយៈពេលមធ្យម និងវែងក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ និងសមិទ្ធផលដទៃផ្សេងៗទៀត ដែលក្រសួងសម្រេចបាន។

សន្និបាត ត្រូវបានរៀបចំឡើងក្រោមរូបភាពជា បទអន្តរាគមន៍ចំនួន១៣ ដែលរួមមាន៖ (១)ការគ្រប់គ្រងមុខងារសាធារណៈ (២)ការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (៣)ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ (៤)ការគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធឌីជីថល (៥)ការជ្រើសរើសមន្ត្រីចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ (៦)ការលើកកម្ពស់ប្រសិទ្ធភាពការងារ (៧)ការរៀបចំប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងឧត្តមភាពសេវាសាធារណៈ (៨)ការវាយតម្លៃ និងអធិការកិច្ចក្នុងវិស័យមុខងារសាធារណៈ (៩) វិធានការ និងផែនការសកម្មភាពនៃការកែទម្រង់រដ្ឋបាលសាធារណៈ(១០)របាយការណ៍វឌ្ឍនភាពឆ្នាំ២០២៣របស់ក្រសួងមុខងារសាធារណៈ (១១)ផែនការប្រតិបត្តិប្រចាំឆ្នាំ និងថវិកា (១២)តួនាទីរបស់មន្ទីរមុខងារសាធារណៈ ក្នុងការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ក្រោមជាតិ (១៣)ការងារសវនកម្មផ្ទៃក្នុង និងការគាំទ្រការអនុវត្តការងារអាទិភាព។ អង្គសន្និបាត បានធ្វើជាវេទិកាពិភាក្សាយ៉ាងផុសផុល ទៅតាមដំណាក់កាលនីមួយៗ ដែលអង្គភាព និងក្រុមការងារជំនាញនានារបស់ ក្រសួងមុខងារសាធារណៈ បានយកចិត្តទុកដាក់ទទួលជាធាតុចូល ដើម្បីការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួននាពេលខាងមុខ។

នារសៀលថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៤ ក្រសួងមុខងារសាធារណៈ ទទួលបានកិត្តិយសដ៏វិសេសវិសាលបំផុតដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីបិទសន្និបាត។

បន្ថែមលើភារកិច្ចស្នូល និងទិសដៅការងារបន្តរបស់ក្រសួងមុខងារសាធារណៈក្នុងការគ្រប់គ្រងអភិវឌ្ឍវិស័យមុខងារសាធារណៈ និងការកែទម្រង់រដ្ឋបាលសាធារណៈ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** បានណែនាំតម្រង់ទិសដល់ក្រសួងមុខងារសាធារណៈក៏ដូចជាគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់លើចំណុចសំខាន់ៗរួមមាន៖ (១)បន្តយកចិត្តទុកដាក់ព្រមទាំងចូលរួមគាំទ្រ និងអនុវត្តឱ្យបានម៉ត់ចត់ក្នុងការកែលម្អការជ្រើសរើសមន្ត្រីចូលបម្រើការងារក្នុងរដ្ឋបាលសាធារណៈប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព **«ជាប់ដោយមោទន ធ្លាក់ដោយអស់ចិត្ត»** ព្រមទាំងជំរុញការរៀបចំ និងការដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជ្រើសរើស និងគ្រប់គ្រងមន្ត្រីបច្ចេកទេស/មន្ត្រីជំនាញ ដែលធានាឱ្យបានដល់ **«ការបំពេញឱ្យត្រូវ ថែរក្សាឱ្យនៅ»** (២)ពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធ មុខងារ តួនាទី និងភារកិច្ចរបស់ខ្លួន ពិសេសត្រូវយកចិត្តទុកដាក់ក្នុងការពិនិត្យ និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធអង្គភាព និងមុខងារមន្ត្រី ដើម្បីពង្រឹងការគ្រប់គ្រង និងការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែប្រសើរប្រកបដោយប្រសិទ្ធភាពខ្ពស់ ពោលគឺ **«ការរៀបចំផ្ទះខ្លួនយើងឱ្យបានស្អាត និងមានរបៀបរៀបរយ»** (៣)ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈសម្រាប់រយៈពេលមធ្យម និងវែង ដោយត្រូវកំណត់ឱ្យបាននូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាក់លាក់ និងច្បាស់លាស់ដើម្បីសម្រេចគោលដៅជាដំណាក់កាលៗឆ្ពោះទៅការកសាងបាននូវរដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ (៤)ក្រសួងមុខងារសាធារណៈ ក្នុងនាមជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ

ត្រូវជំរុញការរៀបចំផែនការសកម្មភាព អនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាល ដើម្បីដាក់ឱ្យអនុវត្តឱ្យបានពេញលេញនូវវិធានការគន្លឹះទាំង៣ (៥)ប្រកាន់ឱ្យខ្ជាប់ខ្ជួននូវ **«អភិក្រមជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»**ក្នុងការដឹកនាំ សម្របសម្រួល រៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីបម្រើផលប្រយោជន៍ប្រជាជនជាធំ និងបម្រើប្រជាជនឱ្យកាន់តែប្រសើរ (៦)ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្ទៃក្នុង ដោយមិនត្រូវទុកបញ្ហាប្រឈម គ្មានដំណោះស្រាយ (៧)ជំរុញការអភិវឌ្ឍសមត្ថភាពមន្ត្រី និងស្ថាប័នជាប្រចាំ (៨)ចូលរួម និងគាំទ្រដល់ដំណើរការកសាងរដ្ឋបាលសាធារណៈឈរលើទស្សនាទាននៃការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម សំដៅ ធានាឱ្យបាននូវការសម្រេចលទ្ធផលដែលអាចគិតទុកជាមុន និងវាយតម្លៃបាន ប្រកបដោយប្រសិទ្ធភាព គុណភាព និងមានការទទួលខុសត្រូវច្បាស់លាស់ក្នុងក្របខណ្ឌនៃការអនុវត្តមុខងារ និងភារកិច្ចក្នុងរដ្ឋបាលសាធារណៈ (៩)យកចិត្តទុកដាក់ ព្រមទាំងជំរុញ និងលើកកម្ពស់ការទទួលយកការសម្របខ្លួន និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងរដ្ឋបាលសាធារណៈ។ ក្នុងឱកាសដ៏ថ្លៃថ្លានេះដែរ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** បានប្រកាសអំពី **«ការដំឡើងថ្នាក់ស្មើនាយកដ្ឋាន ដល់អង្គភាពថ្នាក់ក្រោមជាតិ»** ដើម្បីជាការគាំទ្រ និងលើកទឹកចិត្តដល់អង្គភាពថ្នាក់ក្រោមជាតិដែលត្រូវទទួលមុខងារកាន់តែមានវិសាលភាពធំឡើងក្នុងក្របខណ្ឌនៃការកែទម្រង់របស់រាជរដ្ឋាភិបាល ពិសេសដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ក្រសួងមុខងារសាធារណៈ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជា អនុសាសន៍ណែនាំតម្រង់ទិសដ៏មុតស្រួច និងប្រកបដោយថាមពលដល់ក្រសួងមុខងារសាធារណៈ និងអង្គសន្និបាតទាំងមូល។ ទន្ទឹមនេះ ក្រសួងមុខងារសាធារណៈ សូមគោរពថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃបណ្តាក្រសួង ស្ថាប័ន ទាំងអស់ ដែលបានអញ្ជើញចូលរួមធ្វើឱ្យសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈទទួលបានលទ្ធផលគួរទីមោទនៈ។

សូមអរគុណ!